ក

មាតិកា

I. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៣-៣-២០០៧	-អនុក្រឹត្យលេខ ២១ អនក្រ.បក ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល	២៩៦៣
១៤-៣-២០០៧	-អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការកែសំរួលតួនាទី ភារកិច្ចរបស់នាយកដ្ឋានព័ត៌មានទូទៅ នៃក្រសួងមហាផ្ទៃ	២៩៧០
១២-៣-២០០៧	-អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត	២៩៧៣
១២-៣-២០០៧	-អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៩៧៤
១៣-៣-២០០៧	-អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ	២៩៧៦
១៣-៣-២០០៧	-អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ	២៩៧៧
១៣-៣-២០០៧	-អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់	២៩៧៨

II. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៤-៣-២០០៧	-ប្រកាសលេខ ៣១០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ភី.វ៉ាយ.អ៊ិនធើណេសិនណល បង្កើតសាខារោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ភី.វ៉ាយ.អ៊ិនធើណេសិនណល សាខាទី ១ "	២៩៧៩
១៤-៣-២០០៧	-ប្រកាសលេខ ៣១១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អិនភីស៊ី (ខេមបូឌា) បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "អិនភីស៊ី (ខេមបូឌា)"	២៩៨១
១៤-៣-២០០៧	-ប្រកាសលេខ ៣១២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ូឌីន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) បង្កើតរោងចក្រ " ផលិតផលពីប្លាស្ទិក និងភេសជ្ជៈ " ដែលមានឈ្មោះថា " ម៉ូឌីន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា)"	២៩៨៣

១៤-៣-២០០៧ -ប្រកាសលេខ ៣១៣ ឧវថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ូដឹន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) បង្កើតសាខារោងចក្រ " ផលិតផលពីផ្លាស្ទិក និងភេសជ្ជៈ " ដែលមានឈ្មោះថា " ម៉ូដឹន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) សាខាទី ១ " ២៥៨៥

២_ និស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣២១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡេគុង ខនស្ត្រាក់ធ័រ អេស៊ា (ខេមបូឌា)** ២៥៨៧

០២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ុយ ហុង ត្រេឌីង** ២៥៨៩

០២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉េងហួត (ភីអេច) គ្រុប ខូ អិលធីឌី** ២៥៩១

០២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូ ម៉ាយ អ៊ីមផត អិចផត** ២៥៩៣

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០៩ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **អ៊ិនសាយ អៅ អ៊ិនវេសមេន លីមីធីត (ខេមបូឌា)** " ប្រចាំ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជី នៅប្រទេស អង់គ្លេស ២៥៩៥

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូរី ចទេល ធ្មី** ២៥៩៦

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្វាម អិចប្រេស អ៊ិនធើណេសិនណល អ៊ិន (ឥណ្ឌូឆាយណា)** ២៥៩៨

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ខនឌើរ ត្រាវែល** ២៦០០

គ

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៊ុនថាត ត្រេឌីង** ២៦០២

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រូចេះ ផ្លេន** ២៦០៤

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភូឡូណេត** ២៦០៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣ ខែ វិច្ឆិកាឆ្នាំ ២០០០ ប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំ ឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង សុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីលក្ខខណ្ឌ និង លក្ខណៈវិនិច្ឆ័យ នៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ដែលអនុវត្តសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល គ្រប់ជំនាញនិងគ្រប់កម្រិត ។

ជំពូកទី ២

លក្ខខណ្ឌនៃការបណ្តុះបណ្តាលវិស័យសុខាភិបាល

មាត្រា ៣.-

គ្រឹះស្ថានសិក្សា ដែលមានបំណងបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ត្រូវគោរព និង បំពេញអោយបាននូវលក្ខខណ្ឌ ដូចខាងក្រោម :

- ផែនការយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- រចនាសម្ព័ន្ធគ្រប់គ្រង និង លក្ខខណ្ឌក្នុងការជ្រើសតាំងអ្នកគ្រប់គ្រង កម្មវិធីបណ្តុះបណ្តាល
- កម្មវិធីសិក្សាលំអិត រួមមានខ្លឹមសារ និង ការរៀបចំនៃកម្មវិធីសិក្សានោះ
- សាស្ត្រាចារ្យ រួមមាន គុណវុឌ្ឍិ បទពិសោធន៍បង្រៀន និង បទពិសោធន៍វិជ្ជាជីវៈ
- បន្ទប់សិក្សា បន្ទប់បង្ហាញគ្រាប់ បន្ទប់ពិសោធន៍ និងបណ្ណាល័យ ព្រមទាំង សៀវភៅសិក្សា និង មូលដ្ឋានសម្ភារូបវត្ថុ សម្រាប់បម្រើឱ្យការសិក្សា និងការស្រាវជ្រាវ
- គ្រឹះស្ថានសម្ព័ន្ធ សំរាប់ទ្រទ្រង់កម្មសិក្សាដូចជា មន្ទីរពេទ្យ គ្លីនីកពហុព្យាបាល មជ្ឈមណ្ឌល វិទ្យាស្ថាន មន្ទីរពិសោធន៍ រោងចក្រ សហគ្រាសឱសថ
- សំណុំឯកសារលំអិតផ្សេងទៀត

មាត្រា ៤.-

គ្រឹះស្ថានសិក្សាឯកជន ត្រូវតំកល់ប្រាក់ធានាជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ។ ប្រាក់តំកល់នោះ ត្រូវស្មើនឹង ៥០ ភាគរយ នៃថវិកាផែនការ បី ឆ្នាំ ដើម្បីធានានិរន្តរភាព នៃការបណ្តុះបណ្តាល ។

មាត្រា ៥.-

ចំនួននិស្សិតដែលត្រូវជ្រើសរើសចូលរៀនតាមមុខជំនាញ ព្រមទាំង សូចនាករអនុវត្តន៍ សម្រាប់លក្ខខណ្ឌ និង លក្ខណៈវិនិច្ឆ័យ ដែលចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា ។

ជំពូកទី ៣
លក្ខខណ្ឌសំរាប់ការចូលរៀន និង ការទទួលស្គាល់គុណវុឌ្ឍិ

មាត្រា ៦.-

ការចូលរៀន និងការប្រលងបញ្ចប់ការសិក្សានៅ គ្រប់កម្រិត និងគ្រប់ជំនាញ ក្នុងវិស័យសុខាភិបាលត្រូវមាន ការប្រលងថ្នាក់ជាតិ ។ បេក្ខជនដែលអាចប្រលងចូលរៀនថ្នាក់ឧត្តមសិក្សាបានត្រូវមាន វិញ្ញាបនប័ត្រ ថ្នាក់ឆ្នាំសិក្សា មូលដ្ឋាន ។ បេក្ខជនដែលអាចប្រលងចូលរៀនថ្នាក់មធ្យមសិក្សាបានត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ចំពោះកំរិត និង ជំនាញសុខាភិបាលផ្សេងទៀត ត្រូវគោរពតាមលក្ខខណ្ឌរបស់ ក្រសួងសុខាភិបាល និង ក្រសួង អប់រំ យុវជន និង កីឡា ។ ការប្រលងថ្នាក់ជាតិ ដើម្បីទទួលស្គាល់គុណវុឌ្ឍិ អ្នកបញ្ចប់ថ្នាក់ឧត្តមសិក្សានិងអ្នកបញ្ចប់ថ្នាក់មធ្យមសិក្សា ត្រូវធ្វើឡើងបន្ទាប់ពីការប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យពីគ្រឹះស្ថានបណ្ដុះបណ្ដាល ។

មាត្រា ៧.-

គណៈកម្មាធិការប្រលងថ្នាក់ជាតិ ត្រូវតែងតាំងឡើងដោយរាជរដ្ឋាភិបាល ដែលមានសមាសភាព ដូចខាងក្រោម៖

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី — ប្រធាន
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ទទួលបន្ទុកការងារបណ្ដុះបណ្ដាល — អនុប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា ទទួលបន្ទុកឧត្តមសិក្សា — អនុប្រធាន
- អគ្គលេខាធិការ នៃ គណៈកម្មការធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា — សមាជិក
- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ឬ នាយកគ្រឹះស្ថានសិក្សាសាមី — សមាជិក
- តំណាងគណៈវិជ្ជាជីវៈ ពាក់ព័ន្ធ — សមាជិក
- ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា — សមាជិក

គណៈកម្មាធិការប្រលងថ្នាក់ជាតិនេះ មានលេខាធិការដ្ឋានមួយ ជាជំនួយការ ដែលមានសមាសភាពមកពីនាយកដ្ឋាន ឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា និង នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល ។ លេខាធិការដ្ឋាននេះមានទីតាំងនៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៨.-

គណៈកម្មាធិការប្រលងថ្នាក់ជាតិ ត្រូវរៀបចំ យន្តការនៃការប្រលង គ្រប់កំរិត និង គ្រប់ជំនាញ ដើម្បីធានាអោយការប្រលង មានភាពត្រឹមត្រូវ យុត្តិធម៌ និង តម្លាភាព ជាពិសេសការប្រើប្រាស់ប្រធានវិញ្ញាសារប្រលងតែមួយ សំរាប់គ្រឹះស្ថានសិក្សារដ្ឋ និង គ្រឹះស្ថានសិក្សាឯកជន ។

មាត្រា ៩.-

គណៈកម្មាធិការប្រលងថ្នាក់ជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ជំពូកទី ៤

គន្លង និង កំរិតនៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

ក- ផ្នែកឧត្តមសិក្សា

មាត្រា ១០.-

១. **ផ្នែកវិជ្ជាជីវៈ ថែទាំ ពិនិត្យ ព្យាបាលជម្ងឺ**

១.១ វេជ្ជសាស្ត្រ

១.១.១ ថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ សិក្សារយៈពេលយ៉ាងតិច៦ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ២១០ក្រេឌីត ។

១.១.២ ថ្នាក់ វេជ្ជបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ យ៉ាងតិច ២ឆ្នាំ មានចំនួន ក្រេឌីត សរុបយ៉ាងតិច ៥៤ ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.១.៣ ថ្នាក់ វេជ្ជបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឬ ពីថ្នាក់វេជ្ជបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីត យ៉ាងតិច៦០ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.២ ទន្តវេទនសាស្ត្រ

១.២.១ ថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវេទនសាស្ត្រ សិក្សារយៈពេល យ៉ាងតិច ៥ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ១៨០ក្រេឌីត ។

១.២.២ ថ្នាក់ ទន្តបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវេទនសាស្ត្រ យ៉ាងតិច ២ឆ្នាំ មាន ចំនួន ក្រេឌីតយ៉ាងតិច ៥៤ ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.២.៣ ថ្នាក់ ទន្តបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវេទនសាស្ត្រ ឬ ពីថ្នាក់ទន្តបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីត យ៉ាងតិច ៦០ ក្រេឌីតរួមទាំងនិក្ខេបបទ ។

១.៣ ឱសថសាស្ត្រ

១.៣.១ ថ្នាក់ បរិញ្ញាបត្រឱសថសាស្ត្រ សិក្សារយៈពេល យ៉ាងតិច ៥ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ ឆ្នាំសិក្សាមូលដ្ឋានមានចំនួន ក្រេឌីតសរុប យ៉ាងតិច១៨០ក្រេឌីត ។

១.៣.២ ថ្នាក់ ឱសថបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់បរិញ្ញាប័ត្រឱសថសាស្ត្រ យ៉ាងតិច ២ឆ្នាំ មានចំនួនក្រេឌីតសរុបយ៉ាងតិច ៥៤ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.៣.៣ ថ្នាក់ ឱសថបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រឱសថសាស្ត្រ ឬ ថ្នាក់ឱសថបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីតសរុបយ៉ាងតិច ៦០ ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.៤ ជំនួយវេជ្ជសាស្ត្រ

១.៤.១ ថ្នាក់ បរិញ្ញាប័ត្រគិលានុបដ្ឋាក ថ្នាក់ បរិញ្ញាប័ត្រឆ្មប និង ថ្នាក់ បរិញ្ញាប័ត្រផ្នែកជំនួយវេជ្ជសាស្ត្រដទៃទៀត ត្រូវសិក្សារយៈពេល យ៉ាងតិច ៤ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ១៣០ក្រេឌីត រួមទាំងសារណា ។

១.៤.២ ថ្នាក់ បរិញ្ញាប័ត្រគិលានុបដ្ឋាក ត្រូវសិក្សាបន្ថែមក្រោយពីថ្នាក់បរិញ្ញាប័ត្ររង រយៈពេលយ៉ាងតិច ៣ ឆមាស មានចំនួនក្រេឌីតសរុប យ៉ាងតិច ៤៥ ក្រេឌីត រួមទាំងសារណា ។

២. ផ្នែកសុខភាពសាធារណៈ និង ស្រាវជ្រាវ

២.១ ថ្នាក់ បរិញ្ញាប័ត្រជាន់ខ្ពស់ សុខភាពសាធារណៈ ត្រូវសិក្សាបន្ថែមពីថ្នាក់បរិញ្ញាប័ត្រ វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទសាស្ត្រ បរិញ្ញាប័ត្រគិលានុបដ្ឋាក បរិញ្ញាប័ត្រឆ្មប ឬ បរិញ្ញាប័ត្រជំនួយវេជ្ជសាស្ត្រដ៏ទៃទៀត យ៉ាងតិចរយៈពេល ២ឆ្នាំ មានចំនួនក្រេឌីតសរុប យ៉ាងតិច ៥៤ ក្រេឌីត ។

២.២ ថ្នាក់ បណ្ឌិតវិទ្យាសាស្ត្រ តាមមុខជំនាញនិមួយៗ រួមមាន សុខភាពសាធារណៈ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទសាស្ត្រ ជំនួយវេជ្ជសាស្ត្រ ត្រូវកំណត់ដោយប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា។

ខ. ផ្នែកមធ្យមសិក្សា

មាត្រា ១១.-

ផ្នែកវិជ្ជាជីវៈ ថែទាំ ជម្ងឺ និង ជំនួយវេជ្ជសាស្ត្រ

១. ថ្នាក់ បរិញ្ញាប័ត្ររង ផ្នែកគិលានុបដ្ឋាក ផ្នែកឆ្មប និងផ្នែកជំនួយវេជ្ជសាស្ត្រ ដទៃទៀត ត្រូវសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ មានក្រេឌីតសរុបចំនួនយ៉ាងតិច១០០ក្រេឌីត ។

២. ថ្នាក់ បរិញ្ញាប័ត្ររងឯកទេស ផ្នែកគិលានុបដ្ឋាក ផ្នែកឆ្មប និងផ្នែកជំនួយវេជ្ជសាស្ត្រ ដទៃទៀត ត្រូវសិក្សាបន្ថែមក្រោយពីថ្នាក់បរិញ្ញាប័ត្ររង រយៈពេល យ៉ាងតិចពី ២ ទៅ ៣ ឆមាស មានក្រេឌីតសរុបចំនួន ៣៥ ទៅ ៤៥ ក្រេឌីត តាមឯកទេសនីមួយ ៗ ។

មាត្រា ១២.-

លក្ខខណ្ឌ និង លក្ខណវិនិច្ឆ័យ ស្តីពី គន្លង និង ក៏រិតគ្រប់មុខជំនាញនៃការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល មានចែងលំអិតក្នុងប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ។

ជំពូកទី ៥

លក្ខខណ្ឌ និង ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល

មាត្រា ១៣.-

គ្រឹះស្ថានឧត្តមសិក្សាវិស័យសុខាភិបាលត្រូវគោរពទៅតាមស្តង់ដាអប្បបរមាដូចមានចែងក្នុងមាត្រា ៩ នៃព្រះរាជក្រឹត្យលេខនស-រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៣ស្តីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និង លក្ខខណ្ឌនៃការបណ្តុះបណ្តាលក្នុង វិស័យសុខាភិបាលដែលមានចែង ក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

មាត្រា ១៤.-

គ្រឹះស្ថានមធ្យមសិក្សាវិស័យសុខាភិបាល ត្រូវគោរពទៅតាមលក្ខខណ្ឌនៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

មាត្រា ១៥.-

ការទទួលស្គាល់គុណភាពអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សាវិស័យសុខាភិបាល ជាសមត្ថកិច្ចរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ជំពូកទី ៦

លក្ខខណ្ឌនៃការផ្អាកនិងការបញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

មាត្រា ១៦.-

រាជរដ្ឋាភិបាលធ្វើការសម្រេចផ្អាកជាបណ្តោះអាសន្ន ឬ ការបញ្ឈប់ជាស្ថាពរត្រូវធ្វើឡើងចំពោះគ្រឹះស្ថានឧត្តមសិក្សា ឬគ្រឹះស្ថានមធ្យមសិក្សាណា ដែលមិនគោរពតាមមាត្រា ៣ មាត្រា ៦ និងមាត្រា ១៣ នៃអនុក្រឹត្យនេះ។

ការសំរេចឱ្យផ្អាកបណ្តោះអាសន្ន ឬ ការបញ្ឈប់ជាស្ថាពរត្រូវធ្វើឡើងតាមសំណើពីក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ។

ជំពូកទី ៧

អន្តរប្បញ្ញត្តិ

មាត្រា ១៧.-

គ្រឹះស្ថានបណ្តុះបណ្តាលដែលកំពុងដំណើរការសព្វថ្ងៃត្រូវរៀបចំកែលំអអោយបានតាមលក្ខខណ្ឌ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ លើកលែងតែ និយាមសំរាប់គ្រូ និង អគារសិក្សា ដែលត្រូវបំពេញអោយបានក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ចំពោះកម្មវិធីសិក្សាដែលកំពុងអនុវត្ត ត្រូវរៀបចំកែសំរួលអោយបានតាមកម្មវិធីសិក្សាជាតិដើម្បីអនុវត្តប្រើចាប់ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ១៨.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងអស់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ដូចមាត្រា ១៩
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសំរួលតួនាទី ភារកិច្ចរបស់ នាយកដ្ឋានពត៌មានទូទៅ នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ ..

ត្រូវបានធ្វើការកែសំរួល តួនាទី ភារកិច្ច របស់នាយកដ្ឋានពត៌មានទូទៅ នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ។ ការកែសំរួលនេះ ក្នុងគោលបំណងដើម្បីលើកកំពស់ប្រសិទ្ធភាពការងារបំរើអោយវិស័យសន្តិសុខជាតិ សន្តិសុខសង្គម និងដើម្បីអោយសមស្របទៅនឹងសភាពការណ៍របស់ប្រទេសជាតិនាដំណាក់កាលបច្ចុប្បន្ន ។

មាត្រា២ ..

នាយកដ្ឋានពត៌មានទូទៅ មានតួនាទីធ្វើសេនាធិការជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារស្រាវជ្រាវ ប្រមូលពត៌មានចំហរនិងសំងាត់ ដែលពាក់ព័ន្ធដល់វិស័យសន្តិសុខជាតិ សំដៅរកអោយឃើញនូវសកម្មភាពអមិត្ត សកម្មភាពវិទ្ធង្សនាសង្គម សកម្មភាពល្មើសច្បាប់របស់រដ្ឋ អំពើភេរវកម្ម បទល្មើសឆ្លងដែន បទល្មើសជុំវិញផ្លូវភេទ ហិរញ្ញវត្ថុ និងសកម្មភាពមិនប្រក្រតីនានា ដើម្បីស្នើយោបល់ជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃមានវិធានការ ។

មាត្រា៣ ._

នាយកដ្ឋានពត៌មានទូទៅមានភារកិច្ច ដូចខាងក្រោម :

- ស្រាវជ្រាវប្រមូលពត៌មានជាតិ អន្តរជាតិ ដើម្បីបំរើដល់ការងារសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ។
- ស្រាវជ្រាវប្រមូលពត៌មាន និងតាមដានការងារសន្តិសុខ និងការសំងាត់ជាតិតាមបណ្តាស្ថាប័ន ក្រសួង មន្ទីរ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ ។
- ស្រាវជ្រាវ ស៊ើបបញ្ចាក់ពត៌មាន តាមមធ្យោបាយឧបករណ៍បច្ចេកទេសនិងកំលាំងស៊ើបការ ដើម្បីប្រមូលភស្តុតាង បំរើកិច្ចប្រតិបត្តិការជំនាញនិងការអនុវត្តច្បាប់ ។
- ត្រួតពិនិត្យបច្ចេកទេស បង្ក្រាបបទល្មើស និងហាមពលរដ្ឋខ្មែរចូលបនល្បែង ក្លឹបកំសាន្ត ក្លឹបផ្សងសំណាងស្របច្បាប់គ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ ដើម្បី :
  . ពិនិត្យតាមដានសកម្មភាពលើវិស័យអប់រំវប្បធម៌ សិល្បៈ ប្រពន្ធ័ឃោសនា សេវាកម្ម ផលិតកម្មផ្សព្វផ្សាយចែកចាយពត៌មាន
  . ស្រាវជ្រាវប្រមូលពត៌មានតាមបណ្តាក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានឯកជន និងបណ្តាអង្គការសមាគមមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា
  . ត្រួតពិនិត្យការប្រើប្រាស់ប្រពន្ធ័ប្រៃសណីយ៍និងប្រពន្ធ័ទូរគមនាគមន៍ គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ចូលរួមសហការស្រាវជ្រាវបង្ក្រាប និងដោះស្រាយនូវរាល់ករណីចាំបាច់ ដែលមានវិសាលភាពពាក់ពន្ធ័គ្រប់វិស័យដល់បណ្តាស្ថាប័ន ក្រសួងមន្ទីរ សហគម សាសនា និងខេត្ត ក្រុង តាមបញ្ជាថ្នាក់លើ
- ទំនាក់ទំនងជាមួយបណ្តាស្ថានប័ន ក្រសួងមន្ទីរ គ្រឹះស្ថាន សហគ្រាស អង្គការ សហគម និងអង្គភាពពាក់ពន្ធ័ ផ្តល់នូវឯកសារ តួលេខ និងពត៌មានផ្សេងៗតាមតំរូវការនៃវិធានការស្រាវជ្រាវរបស់ជំនាញនៃករណីនីមួយៗ ដែលថ្នាក់លើ ... គល់រោយ ដើម្បីបូកសរុបរាយការណ៍ជូនថ្នាក់លើពិនិត្យសំរេច
- សហការជាមួយបណ្តាស្ថាប័នរដ្ឋ ឯកជន ដើម្បីកសាងបទដ្ឋាននិងលើកវិធានការការពារសន្តិសុខ សុវត្ថិភាពជូនឥស្សរជនសំខាន់ៗនិងតាមគោលដៅនីមួយៗ
- ប្រមូលពត៌មាន ស្ទាបស្ទង់មតិក្នុងសប្តាហ៍លើព្រឹត្តិការណ៍សំខាន់ៗ ដើម្បីបូកសរុប វាយតំលៃ សន្និដ្ឋានជូនថ្នាក់ ដឹកនាំពិចារណា
- ទំនាក់ទំនងនិងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា តាមរយៈការិយាល័យអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដើម្បីផ្លាស់ប្តូរពត៌មានជាប្រយោជន៍នៃជំនាញ
- បូកសរុប វិភាគពត៌មាន ផ្តើមសុំគោលការណ៍នៃវិធានការណ៍ជំនាញ ដើម្បីរាយការណ៍ជូនថ្នាក់លើពិនិត្យ សំរេច
- តាមដាន ត្រួតពិនិត្យ ណែនាំ ដល់នគរបាលខេត្ត ក្រុងអំពីវិធានការណ៍ជំនាញដែលពាក់ពន្ធ័ដល់កិច្ចប្រតិបត្តិការ ស្រាវជ្រាវប្រមូលពត៌មាន
- ធ្វើផែនការ កសាងសមត្ថភាពធនធានមនុស្ស ទាំងជំនាញភាសារបរទេស និងបច្ចេកទេសវិទ្យាសាស្ត្រទូទៅ

- ប្រជុំដកពិសោធន៍ កែលំអរកិច្ចប្រតិបត្តិការ លើកកំពស់ប្រសិទ្ធិភាពការងារដឹកនាំ និងពង្រឹងការអនុវត្តបទបញ្ជារបស់ថ្នាក់លើ
- ធ្វើការបូកសរុប គ្រប់គ្រងឯកសារ ការងារបុគ្គលិក គណនេយ្យ ភស្តុភាររបស់នាយកដ្ឋាន តាមការកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

មាត្រា៤ ._

នាយកដ្ឋានពតិមានទូទៅ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយ ។

មាត្រា៥ ._

នាយកដ្ឋានពតិមានទូទៅមានការិយាល័យមួយចំនួនចំណុះ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានពតិមានទូទៅ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា៦ ._

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា៧ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ពន្ធ័ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច-ឯកសារ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៩៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៦/៩៤ចុះថ្ងៃទី២៨ខែធ្នូឆ្នាំ១៩៩៦ ស្តីពីការដាក់មន្ទីរពេទ្យកាល់ម៉ែតជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១ : ត្រូវបានបញ្ចប់តំណែងឯកឧត្តម ខា នាយ ពីប្រធានក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែត ដោយចប់អាណត្តិ ។

មាត្រា២ : ត្រូវបានតែងតាំងឯកឧត្តម អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាប្រធាន ក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែតបន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសឯកឧត្តម ខា នាយ ដែលចប់អាណត្តិ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដែលមានចែងក្នុង មាត្រា១ និងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនឯកអគ្គរដ្ឋទូតអូស្ត្រាលី ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍សហប្រតិបត្តិការ AusAID និង ក្រុមគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា CCJAP ចំនួន ០៨ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហការ ជួយជួសជុលកែលំអអគារពន្ធនាគារ ព្រៃស តាមបណ្តាខេត្ត ដូចជា ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម និងខេត្ត កំពង់ឆ្នាំង និងសមិទ្ធិផលនានាជាច្រើនទៀត ក្នុងអាណត្តិទី ២ (ខែ ឧសភា ឆ្នាំ ២០០២ ដល់ខែ ឧសភា ឆ្នាំ ២០០៧) ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនចំពោះ :

១- Ms . Kathryn Elliott លេខាទី២ អភិវឌ្ឍន៍សហប្រតិបត្តិការ AusAID

២- Mr . Robert A.Brandley ប្រធានក្រុមគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា CCJAP

ខ- គ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ជូនចំពោះ :

១- Mr . Ronald Glenn Crannage នាយកគំរោង CCJAP II

គ- គ្រឿងឥស្សរិយយស មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ ជូនចំពោះ :

១- លោក អៀម យុទ្ធ ប្រធានរដ្ឋបាលគំរោង CCJAP II

២- លោក គី ម៉ុនណារ៉ះ ជំនួយការបច្ចេកទេសផ្នែកសុខភាពពន្ធនាគារ

៣- លោក ឡុប គុណបុត្រ ជំនួយការបច្ចេកទេសផ្នែកគ្រប់គ្រងពន្ធនាគារ

៤- លោក ឌ សៀវខេង ជំនួយការបច្ចេកទេសផ្នែកពង្រឹងស្ថាប័ន

៥- លោក ហួត ទេវចាន់ ជំនួយការបច្ចេកទេសផ្នែកទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍
៦- លោក ហេង ហ្សូលី ជំនួយការបច្ចេកទេសផ្នែកបណ្តុះបណ្តាល

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ១ និងមាត្រា ២
រាជកិច្ច កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០០ . អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១. លោកវរសេនីយ៍ទោ **ខុយ ឈីម** អត្តលេខ ០៤៣៥
២. លោកវរសេនីយ៍ទោ **សៀន ឌីណា** អត្តលេខ ០៤៣៦
៣. លោកវរសេនីយ៍ទោ **អ៊ុំ សំអុល** អត្តលេខ ០៤៣៨
៤. លោកវរសេនីយ៍ទោ **សារុន ចាន់ធី** អត្តលេខ ០៤៧១
៥. លោកវរសេនីយ៍ទោ **ស៊ុំ គីរី** អត្តលេខ ០៤៧២
៦. លោកវរសេនីយ៍ទោ **ម៉ាង់ សារិទ្ធ** អត្តលេខ ០៥៣៧ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ ខូ សុគន្ធា អត្តលេខ ០៦១៣
២- លោកវរសេនីយ៍ទោ ឯក សួន អត្តលេខ ០៦១៦
៣- លោកវរសេនីយ៍ទោ ខង់ រិន អត្តលេខ ០៦៧១
៤- លោកវរសេនីយ៍ទោ អ៊ុន ស៊ីណេន អត្តលេខ ០៧១១
៥- លោកវរសេនីយ៍ទោ ទ៉ាន់ ម៉ុន អត្តលេខ ០៨២៨
៦- លោកវរសេនីយ៍ទោ ខ្លូយ សមត្ថា អត្តលេខ ០៩១០
៧- លោកវរសេនីយ៍ទោ សុខ សុផាត អត្តលេខ ០១៧៤៣
៨- លោកវរសេនីយ៍ទោ ឯម រដ្ឋា អត្តលេខ ០២១៦៨
៩- លោកវរសេនីយ៍ទោ អ៊ី ចាន់តុសល អត្តលេខ ០៥០១១
១០- លោកវរសេនីយ៍ទោ អ៊ិន ស៊ីផា អត្តលេខ ០៦៥២២ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៣ ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការដាក់មន្ត្រីរាជការ
ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១ : ត្រូវបានដាក់លោក នុច សែ វរមន្ត្រី ថ្នាក់លេខ ៧ អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣១០ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ២៤៦ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១១.០៤.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១១២៦/០៥ គ.វ.ក ចុះថ្ងៃទី០៦.០៤.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ភី.វ៉ាយ.អ៊ិនធើណេសិនណល ចុះថ្ងៃទី២២.០២.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ភី.វ៉ាយ.អ៊ិនធើណេសិនណល (P.Y. INTERNATIONAL CO., LTD.) តំណាងដោយ លោក HO SIMON CHUN-HSIEN សញ្ជាតិអាមេរិក អាយុ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 112658128 ចុះថ្ងៃទី ២០.០៥.២០០២ បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ភី.វ៉ាយ. អ៊ិនធើណេសិនណល សាខាទី១ (P.Y. INTERNATIONAL BRANCH N°1) " មានទីតាំងស្ថិតនៅ មណ្ឌល១ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh, Phnom Penh, Phone 855 23.211141 . Fax 855 23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុន រយៈពេល១៥ថ្ងៃ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់មិន្នន័យនិងរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៥នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ ៤៦២ ផក.ប្រក ចុះថ្ងៃទី២៣.០៥.១៩៩៧ និង ប្រកាសលេខ ០៩៩ ឧរថកឧ.ប្រក ចុះថ្ងៃទី ២៩.០១.២០០១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ និងសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន " រ៉ាវយន់ ហ្គាមិន ខប" (RAO YUAN GARMENTS CORP.) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ក្រុងព្រះសីហនុ និងប្រធានក្រុមហ៊ុន ភី.វ៉ាយ.អ៊ិនធើណេសិនណល ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងព្រះសីហនុ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣១១ ឧស្ស.ករ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០២ អ.វ ចុះថ្ងៃទី១១.០១.២០០៧ របស់អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ
- យោងលិខិតលេខ ០១៤ ល.អ ចុះថ្ងៃទី១៦.០១.២០០៧ របស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ
- យោងពាក្យស្នើ របស់ក្រុមហ៊ុន អិនភីស៊ី (ខេមបូឌា) ចុះថ្ងៃទី១៤.១២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អិនភីស៊ី (ខេមបូឌា) (NPC (CAMBODIA) LTD.) តំណាងដោយ លោក CHONG YING WAI សញ្ជាតិចិន(ហុងកុង) អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H90117003 ចុះថ្ងៃទី១៦.០៩.២០០១ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " អិនភីស៊ី (ខេមបូឌា) (NPC (CAMBODIA))" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៥ សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23.211141 , Fax : 855 23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អិនភីស៊ី (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣១៧ ឧ.រ.ថ. កន-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១១៨៣/០៥ គ.វ.ក ចុះថ្ងៃទី ១២.០៤.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉ូដឺន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) ចុះថ្ងៃទី២៧.០២.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ូដឺន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) (MODERN PLASTIC & PACKAGING (CAMBODIA) CO., LTD.) តំណាងដោយ លោក SOMSAK RINRUENGSIN សញ្ជាតិថៃ អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ L686594 ចុះថ្ងៃទី២៧.០២.២០០៦ បង្កើតរោងចក្រ "ផលិតផលិតផលពីប្លាស្ទិក និងភេសជ្ជៈ" ដែលមានឈ្មោះថា "ម៉ូដឺន ប្លាស្ទិក & ផាកខេជីង (ខេមបូឌា) (MODERN PLASTIC & PACKAGING (CAMBODIA))" មានទីតាំងស្ថិតនៅដីឡូត៍លេខ៩២៦ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

